អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៣៧.សណ១៨ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ ចន្ទ ១២កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើគម្រោងបន្ថយថ្លៃលក់អគ្គិសនី សម្រាប់តំបន់ចែកចាយរបស់សេវាករផ្គត់ផ្គង់អគ្គិសនីឯកជន ចំនួន ៣១៥ តំបន់ ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ស្ថិតនៅក្នុងរាជធានី-ខេត្ត ចំនួន ២៤ សម្រាប់ខួបនៃឆ្នាំ២០១៨

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនជន **អ្នកប្រើប្រាស់អគ្គិសនី** ដែលបិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់សេវាករឯកជនចំនួន ៣១៥ តំបន់ គ្របដណ្តប់លើភូមិសាស្ត្រ ២៤ រាជធានី-ខេត្ត ត្រូវជា ១៦៥ ស្រុក-ខណ្ឌ ១,២៥០ ឃុំ-សង្កាត់ និងត្រូវជា ១០,៩៤៥ ភូមិ ដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញជាតិរួចហើយ មាននៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តព្រៃវែង ខេត្តស្វាយរៀង ឲ្យបានជ្រាបថា យោងតាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ៤២១.រថ.អវថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០ និងយោងតាមការពិនិត្យវិភាគថ្លៃចំណូល-ចំណាយ ដែលបានធ្វើការគណនា ស្របទៅតាមគោលការណ៍កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី និងបទប្បញ្ញត្តិស្តីពីគោលការណ៍កំណត់ថ្លៃលក់នៅព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងបន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ទាំង ៣១៥ នេះ តាមប្រភេទអតិថិជន និងអត្រាថ្លៃលក់អគ្គិសនីសម្រាប់ខួបឆ្នាំ២០១៨ (វិក្កយបត្រថ្លៃអគ្គិសនីដែលចេញចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩) ដូចខាងក្រោម ៖

| ប្រភេទ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ចាស់ | អត្រាថ្លៃលក់ថ្មី |
|---|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា** | | |
| ប្រើប្រាស់ក្នុង ១ ខែ មិនលើស ១០ kWh | 480រៀល/kWh | 480រៀល/kWh |
| ប្រើប្រាស់ក្នុង ១ ខែ ចាប់ពី ១១ ដល់ ៥០ kWh | 610រៀល/kWh | 610រៀល/kWh |
| ប្រើប្រាស់ក្នុង ១ ខែ ចាប់ពី ៥១ kWh ឡើងទៅ | 790រៀល/kWh | 770រៀល/kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ និងលំនៅដ្ឋានរស់នៅជនបរទេស** | | |
| គ្រប់ទំហំប្រើប្រាស់ | 790រៀល/kWh | 770រៀល/kWh |

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៩២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៦៨៧ ៨៥៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

ទំព័រទី2

| | | |
|---|---|---|
| **៣.អតិថិជនមានលក្ខណៈរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្មទាំងអស់** | | |
| អតិថិជនធុនតូចទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមបណ្តាញចែកចាយតង់ស្យុងទាប | 790រៀល/kWh | 770រៀល/kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមត្រង់ស្វូ របស់អ្នកផ្គត់ផ្គង់ | 0.1819$US/kWh | 0.1786$US/kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមត្រង់ស្វូ របស់អ្នកប្រើប្រាស់ | 0.1719$US/kWh | 0.1706$US/kWh |
| អតិថិជនធុនធំទិញពីនាឡិកាស្ទង់តង់ស្យុងមធ្យមដែលដាក់នៅផ្នែកតង់ស្យុងមធ្យម | 0.1650$US/kWh | 0.1640$US/kWh |
| **៤.បូមទឹកធ្វើកសិកម្ម** | | |
| ប្រើប្រាស់សម្រាប់បូមទឹកធ្វើកសិកម្មពេលយប់ ពីម៉ោង ០៩ យប់ ដល់ម៉ោង ០៧ ព្រឹក | 480រៀល/kWh | 480រៀល/kWh |

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា សូមដាក់ "ឯកសារបន្ថយថ្លៃលក់អគ្គិសនី" នេះ ពិគ្រោះយោបល់ជាសាធារណៈជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ដែលឋិតនៅក្នុងតំបន់ទាំង ៣១៥ តំបន់ ដូចបញ្ជាក់ខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ។ ក្រោយថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨** "ឯកសារបន្ថយថ្លៃលក់អគ្គិសនី" ថ្មីនេះនឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបន្ថយថ្លៃលក់អគ្គិសនីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការបន្ថយថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរ សុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកធ្វើសេវាកម្មចែកចាយផង ។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ **អាជ្ញាធរអគ្គិសនីកម្ពុជា ទីស្នាក់ការផ្គត់ផ្គង់អគ្គិសនីទាំង ៣១៥ តំបន់ សាលារាជធានី-ខេត្ត ២៤ សាលាស្រុក-ខណ្ឌ ១៦៥ និងសាលាឃុំ-សង្កាត់ ១,២៥០** សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់ទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបញ្ជីថ្លៃលក់" ថ្មីនេះ មេត្តាជ្រាបជាព័ត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិទ្ធ**